៨២០- ទឹកម្តងទៀតស្មោះ មិនគួរបើដោះ អញនៅខ្លាចស្រី
បើហៅម្តេច ៗ អញគេចកុំស្តី ទឹងនាងជាគូ
ខុសត្រូវប៉ុន្មាន ។

ពង្សពោធិសត្វ អ្នកគន់គិតកាត់ ហើយដើរទៅថ្កាន
លលោលលះ ទៀបផ្ទះកល្យាណ អ្នករៀបប្រុងប្រាណ
កេកកល់គិតកេ ។

កាលនោះធីតា កេសរមាលា ស្រីស្រស់ស្រគត់
យល់ស្វាមីមឹត ក្នុងចិត្តទុក ញ័រអង្គស្រយុត
អាណិតរៀមរក្ស ។

នាងនាថចរចុះ ពីលើគ្រែនោះ ចេញមកក្រៅដាក់
ចរចារួសរៅ ស្រែកហៅថាអ្នក កំឡោះសោភះ
សុភាពកបកាយ ។

កុំកាលទៅណា អាណិតមេត្តា អញ្ជើញមកអាយ
ចង់ចិញ្ចឹមបាន ខ្ញុំមានសព្វសាយ ចិញ្ចឹមអ្នកអាយ
ខ្ញុំមានមិនខ្វះ ។

៨២៥- ពង្សពុទ្ធចៅ ព្រនាងស្រែកហៅ ទំស្រូតរូតរះ
ស្រាវដើងញ័រញាប់ ប្រញាប់ពេកណាស់ ប្រឹងរត់ផុតផ្ទះ
នៃនាងតោមតាយ ។

ឯនាងធីតា យន់យល់ដេដ្ឋា មិនទៀងមើល.
ប្រមាណក្នុងចិត្ត គ្មានគិតគ្មានស្តាយ គ្មានស្តាប់និយាយ
បន្តិចបន្តួច ។

រីងថៃមត្រួតទុក គានគឹងបើសចុក ពុងពោះគ្រលួច
ក្រឡកឡប់ឡើង ដូចភ្លើងជាលដូច ហេតុចិត្តកាន់កួច
អាល័យស្វាមី ។

ទន់ទោរជ្រោជ្រប់ ដល់ដួលសន្លប់ ពុំដឹងស្មារតី
អស់ខ្ញុំភ័យភាំង ស្ទុះទាំងប្រាំបី មកថ្នាក់ថ្នមស្រី
ចូលក្នុងគ្រឹហា ។

យកទឹកលុបក្ត្រ នាងនាថវល័ក្ខណ៍ បានដឹងកាយា
ទន្ទឹះខ្សឹកខ្សួល អនអួលក កន្ទួងទោបផ្កា
ពុំចេញសួរសេង ។

៨៣០- ឯអស់ទាសី នាងទាំងប្រាំបី ឡោមនាងខ្លួនល្អង
ថាបពិត្រនាង រូបកងឥតគន្លង ប្រាប់យើងខ្ញុំផង
កុំលាក់លៀមឡើយ ។

ប្រការកល់អ្វី ចូរនាងស្រដី ប្រាប់កុំខ្មាសអើយ
ទោះបើម្តេចម្តា យ៉ាងណានាងអើយ ចូរនាងខ្មាស់ឡើយ
ប្រាយប្រាប់ឲ្យស្មោះ ។

ហេតុអ្នកនាង   បានឃើញរូបរាង   នៃអ្នកកំឡោះ
កំសត់នោះណា   យាត្រាទៅឆ្ពោះ   លោធ្មូលដាច់ចុះ
សន្ធប់ឡើនឡន់ ។

ប្តូរនាងប្រាសាទ   កុំកុហកផ្តាស   សូមប្រាប់តាមត្រង់
ឲ្យបានដឹងច្បាស់   យើងសោះគិតស-   ង្ស័យសោះនឹងអន្ត
អ្នកនាងកល្យាណ ។

ទើបនាងឆ្លើយថា   ហៃបងកល់គ្នា   ចាំស្តាប់ពាក្យមាន
អញទុកចិត្តបង   នោះហោងស្នើប្រាណ   នឹងលាក់ពុំបាន
ដូចខ្ទូនវៀចវេរ ។

៩៣៥– លាក់អ៊ុំណាបង   អ្នកនោះឯងហោង   មិនថោកថយទេ
កូនសេដ្ឋីមាន   ធនធានពលរេហ៍   ច្រើនក្រៃនឹងគ្នេ
រាប់ពុំបាន ។

សេដ្ឋីបិតា   អ្នកនោះឯងណា   កាលនោះលោកគ្មាន
បុត្របុត្រា   ជាតិជាប្រធាន   មកធ្វើបុណ្យទាន
នូវវត្តព្រះធាតុ ។

បន់សូមបុត្រា   ជួបនឹងបិតា   នៃអញជាគាំ
ទៅបន់សូមបុត្រ   ចំហុតជាក់ជាតិ   ចូលចិត្តពុំឃ្លាត
សូមគ្នាជាមិត្រ ។

ហើយបានសន្យា   មកនឹងគ្នាថា   បើបានបុត្រពិត
មួយប្រុសមួយស្រី   ដូចនៃគំនិត   គំនូរគូរគិត
ផ្សំឲ្យយកគ្នា ។

ជាមិត្រប្រពន្ធ   លុះប្រកបបុណ្យ   ដូចក្តីប្រាថ្នា
សេដ្ឋីឯនាយ   ធ្វើហ្វាយដីការ   ប្រាប់មកបិតា
នៃអញឯងហោង ។

៩៤០– ឯអន្តបិតា   សឹងធ្វើដីកា   ផ្ញើទៅនៃផ្គង
ថាចាំកូនធំ   ផ្សំផ្គុំជាមួន   មិនឲ្យមានហ្មង
មន្ទិលចិន្តា ។

ជាហេតុកម្មកាយ   សេដ្ឋីឯនាយ   ជាជាតិបិតា
នៃអ្នកប្រុសនោះ   ឈឺលុះមរណា   អន្តរាយទ្រព្យា
សូន្យសុងបង់បាត់ ។

គ្មានគង់ឡើយណា   ទើបអ្នកមាតា   គាត់ដើរហាក់ព្រាត់
នាំកូនប្រុសប្រាណ   សូមទានប្រាកដ   លំបាកឡើយហាក់
ឥតមានល្ហែល្ហើយ ។

នាំកូនមកដល់   ចូលក្នុងសកល   ស្រុកនេះជាក្រោយ
ទំនងជាគត   ពីកាលដើមឡើយ   ដែលមកនោះហើយ
ទើបហ៊ានចូលមក ។

កេបិតាអញ ស្មានគេស្រឡាញ់ ខឹងគិតលៃលក
ឲ្យទ្រព្យរបស់ ស្ត្រីស្មោះរៀបរក ផ្គាត់គំហក
កំហែងជេរថា ។

៧៥- ប្រើគេដេញវៃ ម្តាយគាត់ស្ទើរក្ស័យ រត់ចេញម្នីម្នា
ទៅបាត់សូន្យឈឹង ពុំដឹងទៅណា ឥឡូវឮថា
ម្តាយក្ស័យទៅទៀត ។

ដំណើរនេះហោង លាក់អ្នកបង ទ្រូងជួនបង្អៀត
ជាទុក្ខសព្វថ្ងៃ ស្ទើរក្ស័យបង់ម្សៀត មិនដឹងបើធៀត
ធ្វើម្តេចបានស្បើយ ។

ជាគិះនេះសមខាន សមខាតពុំបាន ជួនជួបមុខឡើយ
ប្រុសដទៃ សព្វថ្ងៃបងអើយ គ្មានចិត្តសោះហើយ
ប្រាប់បងតាមត្រង់ ។

ឥឡូវនេះនៃ ប្អូនលាបងក្ស័យ ថ្ងៃនេះពុំលង់
សេអ្វីកការ អសារសូន្យសុង ប្រាសប្រាណប្រុសម-
ង្គលគាប់ចិត្តហើយ ។

នាងប្រាំបីនាក់ បានស្តាប់នាងជាក់ ភ័យគិតឥតស្បើយ
លួងលោមនាងថា ធីតាម្ចាស់អើយ កុំធ្វើហោះឡើយ
+
ណាំនាងកល្យាណ ។

៤៨០– ខ្លួននាងស្រីពៅ ជាក្មេងណាស់នៅ ទាន់ចាស់ប៉ុន្មាន
ឈប់ចាំមើលព្រេង ភ្លាចក្រែងពុំមាន បានរួមកេប្រាណ
+
ទីពឹងនោះណា ។

នាងស្តាប់តាសី នាងតាំងប្រាំបី លួងលោមចរចា
ហោះហើយនាងគិត ក្នុងចិត្តចិន្តា យល់មែនដូចថា
ទើបឆ្លើយវិញស្នង ។

ថាអស់កល់គ្នា ចង់ឲ្យជន្មា ប្អូនរស់នៅផង
មានតែប្រព្រឹត្ត តាមចិត្តជាម្តង ថាបើអស់បង
ចង់ឲ្យរស់នៅ ។

ទើបតាសីឆ្លើយ ថាអ្នកម្ចាស់អើយ ខ្ញុំតាមស្រីពៅ
នាងប្រើយ៉ាងណា ពានាខ្លួនទៅ លែងតែអ្នកនៅ
ក្រោយយើងខ្ញុំ ។

នាងថាបើបង ព្រមដូច្នេះហោង ចូលចិត្តសុខម
ក្រែងជួនដល់ផ ខឹងត្រូវទោសធំ ប្រយ័ត្នគិតគុំ
ឲ្យកើតកាស្រូវ ។

៤៨៥– ប្អូនបង់ប្រើបង អស់ទាំងនេះហោង ចាំចាប់ឥឡូវ
ឲ្យបានដូចគិត សួរចិត្តឥឡូវ កុំគិតខុសត្រូវ
ចាប់ទៀតបាន ។

តាសីឆ្លើយស្នង ឥឡូវយើងផង តែរៀងកល់ប្រាណ
សុខសឹងក្រមុំ នឹងខំពារពោន ក្រែងមានព្រៀងលាន
គេនឹងនិន្ទា ។

នាងថាកុំភ័យ គិតក្រែងនោះនៃ សឹមប្អូនការពារ
តែឲ្យស្រឡះ ឲ្យជ្រះកល់គ្នា កុំគិតរួញា
ប្អូនធានាឲ្យ ។

ប៉ុណ្ណោះគិតគាន ការក្តីមិនបាន ធ្វើមនុស្សថ្មីឡើយ
ស្លាប់ទៅជាខ្មោច ប្រយោជន៍ជាក្រើយ តាសីស្លាប់ហើយ
ឆ្លើយថាបើប្មោះ ។

ធានាយើងខ្ញុំ នឹងគិតនឹងទំ ពោមពាបអ្នកប្រុស
ចូរនាងកំសាន្ត ឲ្យក្សាន្តចិត្តចុះ ដៃយើងនឹងស្មុះ
ទៅមិនរួចទេ ។

៤៦០– នាងស្តាប់តាសី នាងទាំងប្រាំបី ធានាការយ
បានធូរចិត្តា ធីការះរេ ប្រើថាចងលី-
លាទៅផ្សារធំ ។

មើលប្រុសពិសី គាត់ទៅទិញអ្វី បាត់យូរជ្រង់
ឬមួយដើរលេង ដោយល្បែងលាយឡំ នឹងអស់ក្រមុំ
កំលោះទាំងឡាយ ។

តាសីម្នាក់នោះ ពួនាងប្រើប្មោះ ដើរទៅតែក្រោយ
ញញឹមញញែម ត្រៃហាមព្យសាយ មៀងមើលនាយគាយ
វៀងតាមផ្លូវទៅ ។

លុះដល់ផ្សារធំ ក្រន់ផ្ទះលក់ខំ ឃើញមនុស្សខ្វលខ្មៅ
ទិញដូរនំនែក ទិញបេកអំពៅ ឃើញពោធិទៅ
កំពុងទិញនំ ។

វៀបកប់វិលវិញ មេនោះតេខ្ញាញ់ គេចកាយលាយឡំ
មិនឲ្យពោធិ- សត្វិសេសសម ដឹងហេតុដោយដំ-
ណើរនៃគ្នា ។

៤៦៤– លុះកេលេះ លង់លុះដល់ផ្ទះ ដំកបធីកា
ត្នាងប្រាប់ពុលង់ ឲ្យប្រុងគ្នា ចងក្បិនក្រតា
ក្រវាត់យ៉ាងខ្ជាប់ ។

ទាំងប៉ែត(១)តាសី រៀបខ្លួនទីង ប្រញិបប្រញាប់
ចងពុងពាកបា ក្រៀវក្ដាប់ណាប់ ចំណាន់ចន់ចាប់
នឹងបានដឹងការណ៍ ។

នាងខ្ទះកំប្លង ស្រដីឲ្យកលេង នឹងអស់គ្នីគ្នា
ថាកុំយទំទៀង អស់យើងកល់គ្នា មេច ៗ ទំការ

១—ប៉ែត ពាក្យសៀម ប្រែថាប្រាំបី ។

ប្រយ័ត្នតែដោះ ។

ខ្លួនយើងក្រមុំ ឯប្រុសឧត្តម គាត់ក៏កំឡោះ
កែក្បាត់ចំណាប់ ចាប់ឥតស្រណោះ ប្រញាប់ខ្លួនអស់
នៃវុយកល់គ្នា ។

ចាស្រេចពុំលន់ ទៀយបេញចាំប្រុន សងនានមាតា
ម្ចាន ចូន ម្ចាន ចូន ទាំមួនមហិមា ឯនាងធីតា
សឹងចាំវៃត ។

៨៧០– ពន្លកជិនស្រី អ្នកចិញ្ចំណី បានហើយលៃវ
កាន់ចំកាន់នែក ជ្រៀតជ្រែកកាល់ដៃ ដើរដល់ទំមៃន
នាងនាថកល្យាណ ។

នាងយល់ស្វាមី មានចិត្តប្រណី ពេកពន់ប្រមាណ
ស្ទើរភ្លេចប្រមាត់ ស្រីរក្សំនាន ស្រយុតអង្គប្រាណ
ស្រក់ទឹកនេត្រា ។

ទំនៃស្រែកប្រាប់ ឲ្យតាសីចាប់ នូវអន្តកស្ដា
ថាហ៍គ្នាយើង ឆាប់ឡើងស្រូវ៉ា ចាប់មនុស្សនេះណា
ឲ្យបានកុំលែង ។

តាសីសោកស្ដាប់ ស្ទុះព្រមព្រួតចាប់ ប្រឡូកប្រឡែង
ញើករវិញ ទាញដៃជញ្ជួន ប្រយ័ត្នប្រយែង

ក្រែងរួចរត់បាត់ ។

នាងខ្ទះស្រែកថា ប្រយ័ត្នបក្កា ក្រែងជួនជាទាត់
នាងខ្ទះសោកធ្ងួយ ហង់អើយកុំមាត់ កុំនាំគាំទគាត់
ក្រែងឡើងដោយដៃ ។

៨៧៤– ពោធិសត្វធ្ងួយ ថាទនាងអើយ ខ្ញុំនេះនៃ
ពុំងឹងខ្លួនប្រាណ ជាមានទោសពៃរ៍ មកចាប់វិញ
តើទោសបទណា ។

តាសីពុំស្ដាប់ រឹងជាព្រួតចាប់ រួតរឹតកាយា
ទំសោកខ្លាយខ្លាត ជ្រះបាត់សោះសា អ្នកទំស្រែកថា
ជ្រះទំអស់ហើយ ។

នាងស្រែកទៅក្ដាន ថាចាប់ឲ្យបាន កុំឲ្យរួចឡើយ
អ្នកផ្សារផ្អុកផ្អើល មកមើលជាត្រើយ ចូលជិតបង្កើយ
ដណ្ដឹងទៅថា ។

ចាប់ពីហេតុអ្វី ទើបនាងស្រដី ក្លាយកូនទៅថា
មនុស្សនេះចិត្តច លួចខ្ញុំឯណា ហើយរត់ទៅផ្សារ
គេបបាត់ពីថ្ងៃ ។

ព្រឹកមិញដើរមក ឯងអាត់តែវរ រកចិញ្ចាំវៃស្ស
ដាក់ប្រាក់តាំងចង់ នៅគ្រង់នេះនៃ ពុំបានជាតែ

ជាគិតយ៉ាងណា ។

៤៨០– ស្រាប់តែចូលមក លបលួចឆក់យក ទៅបាត់សោះសា
ខ្ញុំឲ្យទៅតាម គេចភ្លាមក្នុងផ្សារ ឥឡូវទេក្តា
នាំមកឲ្យទាន ។

មីរ៉ុយទាញឡើង ចាប់ចងដៃជើង ឲ្យឆាប់នាំថ្កាន
ទៅឲ្យឆាប់ខ្ញុំ កាត់ក្តីប្រែប្រាណ ពោធិសត្វសាន្ត
ព្រួហើយភិតភ័យ ។

ជាទុក្ខអើយ ខ្ញុំមិនលួចឡើយ ណាអ្នកម្ចាស់ថ្លៃ
សូមអ្នកសន្តោស ប្រាណប្រោសឈិននៃ កុំយកទោសពៃរ៍
អាណិតខ្ញុំផង ។

នាងស្តាប់ហើយណា អាណិតកស្តា ពេកពន់កន្លង
កន្ទេងខ្លាចផ្ស ទុរាន្ទួនល្អង ទឹកនេត្រកន្ទង
អន្ទាមសោះសា ។

ទាំតែអាចអត់ ប្រាណប្រឹងសង្កត់ បំបាត់ទុក្ខា
ស្រែកប្រាប់តាសី ប្រាំបីនាក់ណា ឲ្យនាំយាត្រា
ចរចូលក្នុងផ្ទះ ។

៤៨៥– ឯអស់តាសី ព្រផ្ទះប្អូនៃ នានាំរូតរះ
ចូលក្នុងគ្រឹហា រួចជាស្រឡះ ហើយកំនត្វារស្នុះ

មិនឲ្យចេញបាន ។

ទើបនាងវរល័ក្ខណ៍ ប្រើខ្ញុំពីរនាក់ ឲ្យចរចុះថ្កាន
ចាំផ្លូវសេដ្ឋី ជាបិតាប្រាណ ក្រែងចេញចាកឋាន
មកមើលផ្ទះផ្កា ។

តាសីពីរនោះ ម្នីម្នាចរចុះ ចាំផ្លូវនាងថា
ពីរនាក់ចាំកន មិនមានទៅណា ប្រាំនាក់ជីតា
នាំយកជូនខ្ញុំ ។

លបស្តាប់ពតិមាន ចង់ដឹងដើមដាន ពិតពីស្វាមី
ថៃជាដូចម្តេច កលកិច្ចអ្វី ៗ ទាំងប្រាំតាសី
ទៅតាមចិត្ត ។

ចាំស្តាប់ពាក្យ សែនសោយសោកពី- លាបលន់សោះសា
រៀបរាប់ទំនួញ ខៀវខ្ញួញថៃថា នុះទុកអធិប្ធា
ពុទ្ធោកម្មអើយ ។

៤៩០= កើតមកជាតិនេះ លំបាកអ្វីម្លេះ ព្រះគុណកែវអើយ
ព្រាត់ប្រាសបិតា មាតាជាត្រើយ នៅម្នាក់ឯងហើយ
ហៅសែនវេទនា ។

មកនៅនឹងគេ សព្វថ្ងៃគ្មានល្ហែ គ្មានល្ហើយទុក្ខា
ខះខំផ្គត់ផ្គង់ តម្រង់គាត្នា ប្រយ័ត្នគិតការ

ក្រែងគេប្រមាថ ។

បងខ្ញុំកំព្រា ឯកឥតគ្នា ជាសាច់ជាញាតិ
ខ្ញុំចូលឆ្នាំថ្មី ប្រុសស្រីព្រោងព្រាត គេដើរលេងឆលាត
តែរៀងកល់គ្នា ។

ខ្ញុំនេះទាបគេ មិនហានលេងទេ ត្បិតខ្ញុំកំព្រា
ឥឡូវគេធ្វើ អំពើទោសា កំហែងបំពា
បំពានតាំងស្រស់ ។

ទោះជាគេមាន គេជាម្ដេចបាន សឹងត្រូវតាំងអស់
ខ្ញុំឯងអ្នកក្រ ធ្វើល្អខូចសោះ ពុំដឹងបើដោះ
បើដាក់យ៉ាងណា ។

៥៩៩– ខ្ញុំត្រង់សុខ ១ គេចាប់បំហុក ថាមានទោសា
ប្រាណប្រឹងប្រកែក ដាំដែកម្ដេចម្ដា គេពុំករុណា
ដល់តិចតួចឡើយ ។

នាងនិងពាសី ស្ដាប់ពាក្យពោធិ ខ្ញុំស៊ូប្ដោះហើយ
មានចិត្តអាណិត គន់គិតគ្មានស្បើយ ទៅក្រាណត្រើយ
ចរចូលទៅខ្ទី ។

ដើរដល់ប្រាកដ ហើយនារក្ខ ក្រញ្ញក្រោចសិរសី
ហត្ថាប្រណម្យ បង្គំស្វាមី ហេតុជាតិជាស្រី

គប់នូវទេវលក្ខណ៍ ។

ហើយជាខ្ញុំនេះ ចុះមកសំណោះ ដំរាបសួរអ្នក
អ្នកស្គាល់ដែរឬ ទេអ្នកកុលាក ប្រាប់ខ្ញុំឲ្យជាក់
សោះខ្ញុំសង្ស័យ ។

ពង្សពុទ្ធពោធិ ស្ដាប់ពាក្យទេវី នាងសួរប្រស្រ័យ
និតថានាងនេះ ចំណោះកង់វៃ វែងវេះកែវ
ល្អនលប្រាជ្ញា ។

៦០០– បើអញប្រាប់ពិត សមធនីបានចិត្ត រឹងធ្វើបំពារ
បំពានក្រោកក្រាំង ក្រូចក្រាំងកាយា ក្រែងដួនអាត្មា
អញអត់មិនបាន ។

ចេះគួរគិតតែ ប្រែប្រាប់បំភ័យ ដោយដំណើរប្រាណ
ទើបពោធិសត្វ បុរសរក្ខសព្រាន(១) គតបទៅថ្កាន
នាងនាថធីតា ។

នាងឲ្យតាប់ខ្ញុំ ថាមានទោសធំ ប្រាប់អស់អ្នកផ្សារ
ជាខ្ញុំជាចោរ មោះហោបុស្យា លបលួចទ្រព្យា
នាងទៅតាំងថង់ ។

ឥឡូវមកឡូក មកលបបំអក ប្រែជាទនអង្គ

១–ក្រាំងត្រូវជា <សព្យារ> តែនេះសម្រួលទៅតាមសម្ពស្សកាញ ។

លើកដៃប្រណម្យ   បង្គំគ្រេកគ្រេង   ខ្ញុំមិនទលោកសង្ឃ
ទេកុំសំពះ ៗ

ខ្ញុំមិនស្គាល់ឡើយ   អ្នកនាងម្ចាស់អើយ   ខ្ញុំប្រាប់ឲ្យច្បាស់
សព្វថ្ងៃខ្លួនប្រាណ   ឥតបានឥតផ្ទះ   មានបុណ្យតែព្រះ
អាចារ្យជាគ្រូ ៗ

៦០៩– នោះខ្ញុំស្គាល់ពិត   ព្រោះលោកអាណិត   មេត្តាអាសូរ
នាងសួរពីស្គាល់   ខ្ញុំគាល់ពិតគួរ   ខ្ញុំនៅជាយូរ
ហើយមិនដែលស្គាល់ ៗ

នាងពីកាលណា   កុំនាងចរចា   ឡប់ឡកផ្ចញផ្ចាល់
ខ្ញុំគន់ខ្ញុំគិត   ក្នុងចិត្តពិតកាល់   អន្តិក្កសល់
ឆ្ងល់ហើយឆ្ងល់ឆ្ងាយ ៗ

នាងនាថទេវី   ស្ដាប់ពាក្យពោធី   ទើបឱនអង្គកាយ
សំពះរៀមរក្ស   ថាអ្នកប្រុសកាយ   ខ្ញុំមិនឡកឡាយ
លេងលអ្នកទេ ៗ

ដែលខ្ញុំថាអ្នក   ប្រុសថ្លៃលួចប្រាក់   ខ្ញុំគិតការកេរ្តិ៍
កុំឲ្យសត្តាន   សព្វហ៊ានបិតថេរ   ដឹងហេតុហើយគេ
និងសើចនិន្ទា ៗ

បានជាខ្ញុំក្លែង   ឲ្យតាប់អ្នកឯង   មកតាំងឈ្មោះណា

ព្រោះខ្ញុំស្គាល់អ្នក   ចាំដាក់នេត្រា   ចុះអ្នកមើលថា
មិនស្គាល់ខ្ញុំសោះ ៗ

៦១០– ខ្ញុំសែនឆ្ងាយឆ្ងល់   នឹងអ្នកមិនស្គាល់   ឃើញថាមិនស្មោះ
ចង់តែចង់កៃ   បណ្ដាបណ្ដោះ   កុំធ្វើដល់ម្ល៉ោះ
អាណិតខ្ញុំផង ៗ

បើក្មួយសោះហើយ   អ្នកថ្លៃខ្ញុំអើយ   ស្ដាប់ខ្ញុំសាសង
សួរអ្នកបន្តិច   គន្ធបគន្ធង   តាំងពីដើមទង
ដែលជួបនឹងខ្ញុំ ៗ

ចុះកាលនោះណា   អ្នកនឹងមាតា   លីលាចូលចំ
ផ្ទះខ្ញុំហើយនៃ   សេដ្ឋីធំ   ប្រើគេវាយជំ
ម្ដាយអ្នកស្មើរក្សៀយ ៗ

មាតានឹងអ្នក   រូបរេបញ្ជាក់   លីលាឃ្លាតឃ្លៃ
ខ្ញុំយល់ឪពុក   ធ្វើទុក្ខទោសពៃរ៍   ខ្ញុំគិតមមៃ
មិនមានរហោស្បៀយ ៗ

តាំងពីឪពុក   វាយដំធ្វើទុក្ខ   មាតាអ្នកហើយ
អ្នករត់បាត់ទៅ   ខ្ញុំនៅអ្នកអើយ   កើតទុក្ខគ្មានល្ហើយ
គ្មានល្ហែចិត្តា ៗ

៦១១– ថ្ងៃគង្គិតគង្គល់   តែងគប់ប្រមល់   ក្ដៅក្នុងអុរា

ពីដើមណ្ដាប់ផ្ដាំ ទ្រទ្រាំទុក្ខា ហួនជាដាក់ផ្សារ
ព្រោះចង់ជួបអ្នក ។

អ្នកចាំប្ដូរទេ កុំអ្នកវេះវេរ ប្រាប់ខ្ញុំឲ្យជាក់
តាមដោយខ្លួនពិត សុចរិតកុំលាក់ កុំលៀមទុកដាក់
ធ្វើអ្វីទៀតឡើយ ។

ពន្លកទេសពល ឮនាងនិមិល សួរដូច្នោះហើយ
នឹកដល់មាតា សោកាឥតស្បើយ ពិតពុំលង់ឡើយ
ដល់ដួលសន្លប់ ។

ពុំដឹងស្មារតី ពន្លកជិនស្រី ញ័រអង្គចំប្រប់
នាងភ័យភាំងគិត ប្រឹងរើកទល់ទប់ ហើយយកទឹកលប់
ក្បន់ក្បិតកគ្រា ។

ពោធិសត្វសាន្ត ភ្ញាភ្ញាក់អង្គប្រាណ ដោះឡើងមីម្នា
សញ្ជឹងសញ្ជប់ ទំទប់អង្គា អង្គុយនៅនា
ទីក្រង់នោះនៃ ។

២០– ទើបនាងសួរថា ហេតុកលអ្វីណា អ្នកសោកសង្វៃ
សន្ធឹកញ័រញាប់ ចំប្រប់ស្ទើរក្ស័យ មានបើការល័យ
តាឡោះទៅណា ។

ពោធិសត្វឆ្លើយ ជាទុនាងអើយ ខ្ញុំសោយសោកា

ព្រោះខ្ញុំគន់គិត អាណិតមាតា អ្នកក្ស័យអសារ
សោះសូន្យម្នាក់ឯង ។

ឮអ្នកសួរហើយ ជាអក្ខុមាសអើយ ចង្ខ្ញុំចម្បៀន
ក្បិតខ្លួនគ្រមោច ករណ្ដាបកណ្ដាន តាសូររូបរៃង
កំព្រាទុំពល ។

ពីពាក្យនាងថា មែនពិតហើយណា អ្នកនាងនិមិល
គ្រានោះឯងហើយ នាងអើយខ្ញុំទល់ ទុក្ខទោមនស្សសល់
ថ្ងៃថ្ងឹងពុំបាន ។

នាងសួរទៀតថា ហេតុម្ដេចមាតា អ្នកក្សីណក្ស័យប្រាណ
ចូរអ្នកប្រាយប្រាប់ រៀបរាប់ដោយដាន ដំណើរនិទាន
ឲ្យខ្ញុំដឹងផង ។

៦២៨– ពោធិសត្វឆ្លើយ ជាទុនាងអើយ ម្ដាយខ្ញុំនោះហោង
ទុកពុកនាងវៃ ពីថ្ងៃជាម្ដង រត់រួបរំលង
លុះថ្ងៃព្រព្រឹក ។

សូរ្យសាយរំហូ កាលនោះអកមេ អ្នកមាំទុក្ខា
ទៀបឈើដំណាំ គេដាំនោះណា លង់លុះសន្និយា
ពិតពេលម៉ោង ៨ ។

សានៀមសោតក្ដាក់ ចុះមកគ្រដាក់ ចុកឈាមដោះជាំ

រំដរំផ្លូល ទទួលកាលកម្ម វិបាកនាយនាំ
ក្បីណាក្ប័យផន្ទា ។
ចាកចោលខ្ញុំទៅ នាងអើយខ្ញុំនៅ ម្នាក់ឯងឯកា
ស្រនេះស្រណោច ត្រមោចកំព្រា ឯកឥតគ្នីគ្នា
មួយនឹកផង ។

លុងលុះព្រឹកព្រាន ទទ័យស្រួចស្រាន ពៀនរះចេញចរ
លលាមលលឹម ទឹមព្រឹកក្បាករ ខ្ញុំទ័ត្រជរ
ដើររកទិញក្តារ ។

៦៣០– គ្មានអ្វីទិញឡើយ ទុក្ខតនាងអើយ កាលនោះឯងណា
មានតែក្បូនពេជ្រ មួយពិចា មែនមានមេត្តា
ចនកឲ្យខ្ញុំ ។

ក្បូនពេជ្រទាំងគ្រាប់ បើនឹងរិះរាប់ ប្រមាណទំហំ
ចំប៉ុនមេដៃ ដាក់ក្រៃពិតពុំ ភក្ត្រតណាយចំ
មុសាវាទឡើយ ។

ដើរលក់ក្បូននោះ ដរាបលាន់លុះ ផ្ទះកុដុម្ពីកហើយ
គេយល់ខ្ញុំយំ ស្រៀមក្រពុំស្បើយ គេពុំតោះតើយ
ចាហៅចូលទៅ ។

ខ្ញុំសាតក្រោកករ ម្នីម្នាចូលចរ ទទនអន្តុយទៅ

កុដុម្ពីកសោមនស្ស ស្ត្រីស្មោះពៅកើ សួរសព្វឥតសៅ-
ហ្មងមន្ទិលឡើយ ។

ក្បូនពេជ្រនោះកូរ គេទិញទុកទៅ ឲ្យក្តារមួយហើយ
ឲ្យមនុស្សជញ្ជូន សែងជូនជាក្រោយ ដល់ទៅនាងអើយ
ខ្ទមខ្ញុំនេះណា ។

៦៣៤– រកកន្ទុលស្បែក នឹងកាត់នឹងហែក ច្រូច្រាប់បាតក្តារ
លាក់អ្វីខ្ញុំបាទ ស្រាតខោអាត្មា ក្រាលឲ្យមាតា
ដោយខ្លួនទីទ័ល ។

គេថែលផ្លួយសែង ក្តារទៅនោះឯង ផ្លួយលើកសពផ្តល់
ហើយមកផ្ទះបាត់ ខ្ញុំស្ងាត់សូន្យសល់ ររះរកកល
កាច់អស់ឈើព្រៃ ។

ប្រក់ធ្វើជាម្ចប់ ពោះថ្ងៃពោះយប់ ខ្ញុំនៅនោះនៃ
ដេកចាំមាតា វេទនាពេកក្រៃ សំពត់អាវស្បៃ
រកស្លៀកពាក់គ្មាន ។

លាក់អ្វីអ្នកនាង វេលាព្រឹកព្រាង ខ្ញុំដើរសូមទាន
ស្លៀកតែស្រទប- ចេកក្តាបតែប្រាណ ដើរដោយកានកាន
ផ្ទះគេទាំងគ្រប់ ។

ខ្ញុំចាំអ្នកម្តាយ នៅបីរឆ្ងាយ ទាំងថ្ងៃទាំងយប់

ផ្លូវក្បៀនផ្ការ ធ្លាក់មកគ្មានឈប់ រសាប់ប្រប់
ច្រើនចាំពុំបាន ។

៦៤០– ហើយណាមាតា ចរចេញលីលា ចុះមកដល់ឋាន
លោកគ្រូអាចារ្យ មេត្តាប្រោសប្រាណ លោកក៏ឲ្យទាន
សំពត់នេះណា ។

កញ្ចាស់នៅជាំ ស្លៀកជាង ១០ ឆ្នាំ នេះហើយពីតា
នាងនាថបានស្តាប់ សាសព្ទផង្ហា នាងសោយសោកា
ពន្ធឹកពេកក្រៃ ។

ពុំអាចទុលទប់ ជាលដល់សន្ធប់ ជីវិតស្ទើរក្ស័យ
តាសីតាំងប្រាំ ព្រួយព្រួនគិតភ័យ ចាប់យកទឹកវៃ
ក្សន់ក្សិតកន្ត្រា ។

នាងដឹងស្មារតី សោកសល់សែនទ្វី ភាណិតភាទាថ
ភាណោចលើសលន់ ពេកពន់ណាសំណា ថៃងចេញចរចា
ថាទុប្រុសថ្លៃ ។

កម្មអើយពីម្ល៉េះ មិនមានរបេះ របូតឡើយខៃ
ជួនយល់អ្នកហើយ អ្នកអើយជួនវៃ ជួនគិតរំពៃ
ពើនវៃថា ។

៦៤៥– អ្នកប្រុសត្រូវព្រាន វៃនឹងខ្ញុំឯង ខ្ញុំអបចិន្តា

ខ្ញុំឲ្យហៅគេ អ្នកម្តុកនេះណា ជិនឲ្យប្រព្យា
សំពត់ការវៃស្យ ។

បានមកដល់ហើយ ម្ដេចអ្នកតោះតើយ មិនមានសង្ស័យ
រត់ទៅស្មោះស្មាន មិនមានអាល័យ ឬអ្នកណាយចៃ(១)
ពីព្រោះខ្ញុំថា ។

ដាក់ទានឲ្យអ្នក ហេតុអីអន់អាក់ ពុំយកឡើយណា
ខ្ញុំឥតប្រមាថ ផនជាតិពាលា ខ្លាចអ្នកនាថា
គេដឹងទំនង ។

ជាប្ដីប្រពន្ធ វៃក្រែងគេរិះគន់ កើតក្តីសៅហ្មង
មិនបាត់មិនស្ងាត់ កើតមាត់កផង ភោរឡូអឹងកង
ដឹងដល់បិតា ។

ឬមួយគិតទីង ជាខ្ញុំខ្ញឹន ចិត្តកាចឫស្យា
ដូចអន្ធពុក ពុំទុកចិន្តា ឡើយទើបបានជា
វៃគេចពុំយក ។

៦៥០– ពោធិសត្វឆ្ងៀយ ចាំទុនាងអើយ នាងឲ្យហៅគេ
កប់ការទំបាច សត្វិតហៅមក ហៅមានអបេក្ខា
អក្យាស្រីយស្រី ។

១– ពាក្យសៀម ណាយចិត្ត ។

អាចកែអាចគិត អាចកាន់សុចរិត សង្គំខន្តី
អាចមានចិន្តា មេត្តាមេត្រី មកត្រេកប្រណី
ជឿចូលចិត្តហើយ ។

ខ្ញុំមិនគិតប្លោះ គិតក្លៃជួបដោះ គួចខន់ចិត្តឡើយ
ខ្ញុំគន់គិតគ្លោះ ដឹងតែនាងអើយ នាងគិតត្រូវហើយ
ត្រូវត្រង់គន្ធ ។

ក្រឡេបគេចកែ គេចគិតបៀតបែរ តាមដោយចំនង
ដំណើរនាងគិត នាងគួរឡើយហោង ហើយហេតុចិត្តចង
ចិត្តចាប់មេត្រី ។

ដែលខ្ញុំព្រាត់ មិនយកសំពត់ សំពាយពស្រី
មានស្រុកនៅឆាយ មានកាយសេដ្ឋី សេដ្ឋាជាផ-
សួរសព្វជគា ។

៦៥៩– ខ្ញុំខ្លាចពុំហ៊ាន ទទួលយកបាន យកទៅក្រែងមហា
សេដ្ឋីជាធំ ដឹងដំណើរណា ថានាងធីតា
ឲ្យសំពត់ខ្ញុំ ។

បានលើចំណាប់ ចំណង់ស្អប់ស្រាប់ ពើបលើដំណើ
ទំនងមានមក សង្សៀកកាយធំ កាយដល់ក្រែលក្រ
ស្លាប់ខ្លួនអសារ ។

សោះសូន្យឥតត្រើយ ឥតអ្នកណាឡើយ ទឹងជួយការពារ
ការពារទោសទុក្ខ ទោសធាន់ធាន ក្បែរកាតខ្លាចមហា-
សេដ្ឋីជាធំ ។

អ្នកណាទឹងហ៊ាន ចូលហួសចូលថ្កាន ចូលចុះជំនុំ
ចំនួសផ្ទែក ផ្ទុះផែនដី វៃផ្ទឹមជួយទោសខ្ញុំ
ឲ្យរួចគ្មានឡើយ ។

ខ្ញុំមិនគួចចិត្ត ដូចជានាងគិត ទេណាំនាងអើយ
នាងកុំសង្ស័យ សូមថ្ងៃលំហើយ លំហែឲ្យស្បើយ
ឲ្យល្ហើយទុក្ខា ។

៦៦០– ទើបនាងឆ្លើយឆ្លៀត ឆ្លើយឆ្លងទៅទៀត សំណោះសួរសា
សួរសុខទុំនៃ ថាហៃប្រុសក្ខា ប្រុសប្រាប់ប្អូនកំ
ប្អូនរង់ចាំស្ដាប់ ។

កុំឲ្យជាខ្ញុំ នឹងប្អូនល្ហោះក៏ យល់ត្អូងនឹងច្បាប់
ធម្មតាជាប្ដី សំដីសណ្ដាប់ សំដែងដោយគាប់
សមគួរនឹងប្រាណ ។

អ្នកប្រាប់ដោយពិត តាមដោយសុចរិត តាមធម៌ករុណ
ចិត្តអ្នកសព្វថ្ងៃ កាល័យស្មោះស្មាន ស្ម័គ្រចិត្តគិតគាន
គិតប្អូនឬទេ ? ។

ឬមួយកាត់ចិត្ត   កាត់ចោលគ្មានគិត   គ្មានស្គាល់ស្និទ្ធស្នេហ៍
បិតទៅចង់បាន   ចង់បទបុព្វ   បពិត្រអ្នករ
អ្នករិះគិតខ្ញុំ ។

ពោធិសត្វជា   ហៃប្អូនសង្សារ   បុណ្យជាក់ចំ
ជាក់ជាគួគាប់   គួរគិតស័ក្តិសម   ស័ក្តិសួរដោយផង
ដោយដានចិត្តបង ។

៦៦៥– ចិត្តបាននឹងរៀម   នឹងរិះរំលៀម   ព្រាកខ្លួនល្អង
ខ្លួនល្អចំណាប់   ចំណានស្នេហ៍ស្នង   ឲ្យដឹងទំនង
ដំណើររៀមរ័ក្ស ។

រៀមនែនកាល័យ   អាឡោះសព្វថ្ងៃ   ចិត្តចាំស្មោះស្ម័គ្រ
ស្មោះស្មើជីវិត   ជីវិតជាក់   ចង់ជួបនុជអ្នក
នុជខ្លួនកុំឆា ។

ចាំតែពាល់ពាក់   ពាល់ត្បិតធុរៈ   ខុរង់កព្រា
កំព្រានម្នាក់ឯង   កណ្តៃងឥតគ្នា   ឥតទាំងទ្រព្យា
ឥតឪពុកម្តាយ ។

ឥតទីពុំនាក់   ពុំទឹងពឹងពាក់   ពឹងចាំនាំកាយ
នាំគិតឲ្យបាន   រួមហានតោមតាយ   តោមដើរនៅកាយ
នៅឲ្យសុខសាន្ត ។

ហេតុនោះរូបរៀម   រូបវង់ទុក្ខក្រៀម   ទុក្ខក្រំក្នុងប្រាណ
មិនចង់ឃើញស្ងួន   នឹមខ្លួនកល្យាណ   កល្យាណ៍យៅវមាន
យៅវមិត្រសង្សារ ។

៦៧០– សង្ស័យក្នុងកាយ   ក្នុងចិត្តសោកស្តាយ   សោកសព្វវេលា
នឹកស្តាយវិស័យ   សព្វថ្ងៃវេទនា   និត្យនៅកព្រា
កំព្រានប្រាណព្រួន ។

ព្រួយព្រានថៃថប់   ថៃថេះដេកយប់   ដេកយល់សប្តិស្ងួន
សប្តិសោតឃើញដល់   ឃើញជួបនឹងខ្លួន   នឹងអ្នកប្អូនស្ងួន
ប្អូនស្ងាត់ម្នាក់ឯង ។

ភ្ញាក់ឡើងកាលណា   កាលនោះសោកា   សោកគិតសង្រេង
សង្រែខ្លួនខ្មោច   កណ្តាចកណ្តែង   កណ្តុកចិត្តតែង
តែងទល់ទុក្ខា ។

គឺមោះទំអត់   ទំនុនសង្កត់   សង្កៀតកាយា
កាយិន្ទ្រិយផង់   តម្រង់ចិន្តា   រំសាយសោកា
មិនឲ្យគេដឹង ។

ពិតប៉ុណ្ណេះហើយ   អ្នកមាសបងអើយ   សូមប្អូនព្រលឹង
នាងកំសាន្តចិត្ត   កុំគិតរំពឹង   រំពៃថានឹង
បានបង់ឡើយណា ។

៦៧៩– ចូរចាំយកប្ដី យកប្រុសដទៃ តាមចិត្តបិតា
មាតានៃអ្នក ស្មោះស្ម័គ្រត្រង់ណា ត្រង់នោះកស្ដា
គួរគូប្រាជ្ញផ្ចុ ។

កុំគិតសង្ហារ សង្ស័យវេជ្ជា ទុកចិត្តជាប្ដី
ព្រេងអស់ម្ល៉េះហើយ ស្ងួនអើយកុំបី បង់ចិត្តមេត្រី
ដូចកាលមុនឡើយ ។

ខ្លួនបងកំព្រា ដូចប្អូនស្ងួនភ្ងា ខានជីនស្រាប់ហើយ
ក្រពន់ក្រពោក ចំឡែកប្អូនអើយ គួរប្អូនតោះតើយ
កាត់ចិត្តចោលទៅ ។

កាលនោះស្រីស្ងួន កេសរនមនួន បានស្ដាប់បមទៅ
កក្ដាស្រពោន បង្អោនខ្លួនទៅ អន្ទុយសោកសៅ
ស្ដីស្ទើរមិនចេញ ។

សញ្ជឹងសញ្ជប់ ដង្ហើមធំថប់ កើតទុក្ខម្នោម្នញ
បង្អៀតទុក ឈឺផ្សាតេកពេញ ទំនាស់ឆ្ងើយវិញ
ជាប្រុសប្អូនអើយ ។

៦៨០– កូនលោកយនេះ ជាចោរចេះ រចូតអ្នកហើយ
ប្រុសដទៃ កុំបីអ្នកអើយ ស្លាប់ទៅជាក្រោយ
ជាជាងរស់នៅ ។

អ្នកកុំបញ្ឆោរ បញ្ឆោះបំពោរ បំពោតប្អូនពៅ
ប្អូនកុំដូចស្រី ដទៃទៀតទៅ ទៀតទេកុំនូវ
កុំឆយាំងនោះ ។

តែស្រីចណ្ដាល ចេកចោរស្រើបស្រាល ស្រើករញ្ជួះ
ឃើញប្រុសទៀតមាន ធនធានសព្វសុស មិនគិតគាប់ខុស
ចេញចោលប្ដីដើម ។

គ្សិតឃើញប្ដីក្រ ប្ដីរូបមិនល្អ មិនស្ងូវជ្រលជ្រើម
នឹងកាមតណ្ហា ប្រែជាស្អប់ខ្ពើម មុខខ្ញាញ់ញើម
ផ្ទូរកទៀត ។

រកទីសប្បាយ ដោយចិត្តភាយមាយ ចេកចោលចង់មៀត
មិនគិតកេរ្ដិ៍ខ្មាស ប្រឡូះគ្នាស់ឆ្ងៀត សសៀរសិកសៀត
សសៀបពីរបី ។

៦៨៩– រីឯចិត្តប្អូន ចិត្តអ្នកសុខស្ងួន តែប្រុសពិសី
ពិសេសជាឆ្មើម ជាថ្មើមប្អូនស្រី បើក្ងជាតី
លោកយនេះណា ។

ខានបានជួបជាក់ ជួបជួនទឹងអ្នក ណ្ហើយខ្ញុំសូមលា
អ្នកនឹងស្លាប់ទៅ ឥឡូវនេះណា កុំអ្នកគិតជា
ប្អូននៅរស់ឡើយ ។

តែជាតិនេះណា យើងបានជួបគ្នា ជាគូទៅហើយ
អនាគតជាតិ កុំឃ្លៀងឃ្លាតឡើយ សូមជួយជាត្រើយ
រៀងដល់និព្វាន ។

បើខ្ញុំស្លាប់ទៅ អ្នកប្រុសប្អូននៅ ធ្វើបុណ្យឲ្យទាន
ស្លៀកសកាន់សីល កុំខ្វល់ក្នុងប្រាណ ប្រាជ្ញាឲ្យបាន
ជួបជួនប្អូនស្រី ។

នាងថាម្ល៉ោះបាន ននៀលប្រះប្រាណ ប្រះប្របស្វាមី
ស្រយុតអស់អង្គ ខ្សឹកខ្សួលស្មារតី សោយសោកឥតថី
ឥតបើគណនា ។

៦៩០– ពន្លកបមពង្ស បមពោធិវង្ស យល់នាងសោកា
សោកជិតខិនក្ស័យ ប្រល័យអសារ អសោចព្រោះណា
ព្រោះអ្នកគន់គិត ។

គន់គួរប្រណី ខ្សឿយណាស់ហើយស្តី ថាហៃមាសមិត្រ
មាសមាននេត្តា មេតែងអាណិត អនាថចាំចិត្ត
ចាំចងស្នេហា ។

ស្នេហ៍ហេតុកន្ទង ចំណាំនឹងចង ពិតពីបុកណ៌
ចរមនាយនោះ នឹកស្មោះប្រាជ្ញា នាងស្តាប់រៀមរ៉ា
រៀមនឹងនិយាយ ។

ប្អូនអើយកុំស្ងួន គិតធ្វើកម្មខ្លួន ព្រោះណាំនាងកាយ
ចូលកែវកំសាន្ត ឲ្យបានសប្បាយ ទឹករកកែកាយ
កែគិតជាថ្មី ។

នាងស្តាប់រៀមរក្ស លួងលោមស្មោះស្ម័គ្រ ដោយពាក្យមេត្រី
បន្ទូរសោកស្រាង តាមពាក្យស្វាមី ដោះឡើងហើយស្រី
ទុនអង្គការយេ ។

៦៩៤– លើកដៃសំពះ សួរថាអ្នកម្ចាស់ អ្នករៀមវិរះ
រិះរកកលការណ៍ យ៉ាងណាប្រុសស្នេហ៍ ប្រុសស្និទ្ធជួយកែ
ជួយគិតប្អូនស្រី ។

ទើបពោធិ៍ថា ហៃប្អូនសង្សារ សំឡាញ់ក្រាប្រិយ
កុំនាងជាទុក្ខ វិតក្កធ្វើអ្វី ចូរប្រុងស្មារតី
តែងតាមពាក្យបង ។

កុំអាលផ្តាច់ជន្ម ផ្តាច់ចិត្តឲ្យអន់ ឲ្យអាប់មុខបង
មុខមាសបណ្តូល បណ្តាច់ស្នេហ៍ស្ងួន ក្រែងអស់អ្នកផង
គេនឹងនិន្ទា ។

ជាប្អូនពិសី យំចង់បានប្តី ទាល់តែមរណា
មរណាំតាំងអង្គ បាត់បង់ឃ្លាតឃ្លា ឃ្លាតឃ្លៀងអសារ
អសោចអង្គកាយ ។

រូបកើតវេទនា   វេកទោសា   ទោសោវៃឆ្ងាយ
ហេតុដូច្នោះហោង   ចិត្តបងស្ងួនកាយ   ចង់ឃាត់នោមឆាយ
នោមធើតឲ្យនៅ ។

៧០០– ឲ្យនាំងប្អូនឯង   ប្អូនអត់ចាំព្រេង   ចាំមើលតទៅ
តទៀតឯមុខ   ព្រេងកុសលពៅ   នៃនឹងបងទៅ
បងចាំតូចស្ងួន ។

នាងស្តាប់ពោធិ   មានពាក្យស្រដី   រំឭកនាងស្ងួន
នាងនឹកក្រេកអរ   ក្រេកអស់ក្នុងខ្លួន   ស្បើយថប់ថៃជួន
ថៃជាអ្នកអើយ ។

អ្នកគិតដូច្នោះគាប់   ព្រោះគួរនឹងច្បាប់   ចូលចិត្តប្អូនហើយ
ព្រោះប្អូននឹងព្រាំ   បងចាំជាត្រើយ   ជាបរៀនហើយ
រៀនកល់ឆ្នាំទៅ ។

កុំជាតែក្មេង   ពោះចាស់វង្វេង   ឆ្មេញបាក់សក់ស្កូវ
កំគង់តែចាំ   ចំកំប្រុសពៅ   ប្រុសពិតពេញទៅ
ពេញនឹងសំណាង ។

សំណូមសូមសំខ   សូមបានដូចចិត្ត   ដូចជាសេពសាង
សេពសូមមិត្រមូល   ជួបចូលរួបរាង   រួមរស់សពាង្គ
សារពើកុំឃ្លាត ។

៧០៩– ពោធិ៍នូវនាង   និយាយសូមសាង   សច្ចាជាក់ជាតិ
ជាក់ជៀចិត្ត   ហើយណានាងនាថ   ទនអន្តអភិវ
អភិវឌ្ឍន៍រៀមរក្ស ។

ហើយទើបនាងប្រើ   ទាសីឲ្យធ្វើ   ភោជនជាតជាក់
សម្លចិនសៀម   នាក្រៀមគ្រឿងគ្រាក់   សាច់ក្រកក្រលដាក់
កាហ្វែណោមខ្ទូវ ។

ទឹកគ្រឿងអន្លក់   បន្លែលៀបជ្រក់   សព្វគ្រប់គ្រឿងគ្រៅ
ដួសដាក់លើតុ   លើទឹកតសៅ   សុទ្ធសឹងក្តៅ ។
សោយសព្វអាហារ ។

ទេវីវរលក្ខណ៍   វរល្អងរៀមរក្ស   រៀមរួមភស្តា
សំណេះស្នាស់ឆ្លើយ   អ្នកអើយពិសា   អស់ចាំងក្រយា
ឲ្យសុខក្សេមក្សាន្ត ។

ពោធិ៍សព្វឆ្លើយ   ទៀតទ្វាស់ថាណ្ហើយ   នាងប្អូនកល្យាណ
នាងឯងហូបទៅ   នោមផ្ទៅយៅវិមាន   ឯអន្តុបងបាន
បរិភោគរួចហើយ ។

៧១០– កែវកុំព្រួយចិត្ត   បារម្ភគនគិត   នៃនឹងបងឡើយ
បងលាក់ធ្វើអ្វី   ណាស្រីបងអើយ   បងគិតជាត្រើយ
តែត្រឹមមាតា ។

ក្បិតពីថ្ងៃនោះ លោកគ្រូសង្គ្រោះ មែនមានមេត្តា
លោកឲ្យទាំងប្រាក់ មួយកាក់មកណា បង្គាប់បងថា
ឲ្យលេងនឹងគេ ។

បងគិតតែថា យន់យល់ឥតការ ឥតកោះឥតក្តើ
លេងឥតប្រយោជន៍ អសោចសូន្យទេ សូន្យទាំងកាយ
កាយិន្ទ្រិយ៍ ។

ហេតុនោះបងអ្នក យកប្រាក់មួយកាក់ ទៅទិញនំបុ័ង
នំក្រូចនំក្រៀប ផ្លែទៀបបារាំង អន្សមជ្រូកអាំង
នូវនំទាំងឡាយ ។

នឹងយកទៅព្រៃ ប្រយោជន៍ដើម្បី សែនជូនអ្នកម្តាយ
កាលនាងឲ្យចាប់ ក្រឡាប់ខ្ចាត់ខ្ចាយ ជ្រុះអស់អន្តរាយ
គ្មានគង់តិចឡើយ ។

៨១៩- ទើបនាងនាថថា ឱប្រុសស្នេហា សំឡាញ់ប្អូនអើយ
ប្អូនសូមទោសា ស្មាលាអ្នកអើយ សូមអ្នកលំហើយ
លំហែទោសទុក្ខ ។

លែងតែមេត្តា អាណិតពិសា អាហារម្ហូប
រួមទាំងនឹងប្អូន ឲ្យសាន្តឲ្យសុខ បំណាច់ជួបមុខ
ជួបមាតបានអង្គ ។

អស់ចំណី នោះអ្នកកុំភ័យ ប៉ុណ្ណោះឡើយហោង
សូមប្អូនរៀបចំ ឲ្យសមហ្មត់ហ្មង កុំបីអ្នកបង
អ្នកព្រួយគំនិត ។

ពង្សព្រហ្មឧត្តម យល់នាងបង្គំ នោះពន់ពេកពិត
ពេកពេញចិន្តា ស្នេហាអាណិត អាណោចពន់គិត
ទើបបរិភោក្តា ។

ឯនាងកល្យាណ នាងខ្មាសមិនហ៊ាន បរិភោគឡើយណា
តែងអង្គុយជិត វរមិត្រកន្តា បែរបេះអាហារ
មៀនមើលផ្អឹងផ្អែង ។

៨២០. ឯសេដ្ឋីបុត្រ ពូជពង្សវង្សព្រុ- ឧក្ខូរតម្តង
អ្នកបរិភោក្តា ហើយណាលេញលេង ចាំអស់អ្នកឯង
អ្នកហុចប្អូនពៅ ។

បងនឹងតែឯង ក្នុងចិត្តចាំចែង ខ្មាសនាងប្អូនពៅ
អញ្ជើញភោក្តា ផងស្ងាត់ខ្លូវ កុំគិតខុសត្រូវ
អៀនខ្មាសឡើយណា ។

ពីដើមហៅបង ឲ្យបរិភោគផង រួមនឹងកនិដ្ឋ
ឯខ្លួនមាសស្នេហ៍ លោប្រកាឡា គិតមិនភោក្តា
តើគិតកលអ្វី ។

ឬក្រែងខ្ពើមបង ត្បិតបងសៅហ្មង អង្គកាប់អប្រិយ
នាងថាទេអ្នក វរលក្ខណ៍ពិសី ខ្ញុំគ្មានគិតអ្វី
ដូចមានប្រសាសន៍ ។

បើខ្ញុំខ្ពើមហើយ ធ្វើអ្វីម្លោះឡើយ តែផ្ដេសតែផ្ដាស
ឲ្យប្អូនអាប់មុខ អ្នកស្រុកពេញពាស រាល់បណ្ដារាស្ត្រ
សើចតាំងប្រុសស្រី ។

៧២៩- ហេតុតែអាល័យ ការឡោះអ្នកថ្លៃ ចិន្តាបេតី
មិនគិតនរណា ថៃជាអ្វី ៗ ព្រោះត្បិតមេត្រី
ត្រេកអ្នកប្រុសគន់ ។

ប្រុសតូចកុំគិត បារម្ភន់គិត ក្រែងប្អូនជិនឆ្អន់
រអើមខ្ពើមអ្នក ឬអ្នកអៀនអន់ មិនល្មោះប្រុសគន់
ទេកុំសង្ស័យ ។

តែប្អូនពុំហ៊ាន ចូលទទួលពាន ជាមួយអ្នកថ្លៃ
ភ្លាចក្រែងឆ្លងច្បាប់ ទម្លាប់មុននៃ សូមអធ្យាស្រ័យ
ក្សានចិត្តប្អូនផង ។

ពោលសព្វថា ហៃប្អូនសង្សារ សំឡាញ់ស្នេហ៍ស្នង
ជាលេសមេត្រី កុំបន្ទួនល្អង បារម្ភនឹងបង
ស្ដីចុំណោះឯង ។

លុះអ្នកភោក្ដា រួចស្រេចហើយណា នាងនាថតាក់តែង
បៀកស្លាបារី ជូនប្ដីហើយថែង ចាត់ចៅនោះឯង
ឲ្យយកចំណី ។

៧៣០- គ្រប់មុខមានពណ៌ សុទ្ធសឹងល្អ ៗ គ្រកាលពិសី
ដាក់ក្នុងកន្តាន ចំពោងថ្មី ៗ រៀបរកកែវ
ជាក្បួនក្បាច់ក្បូរ ។

រៀបរួចស្រេចហើយ ពិតពុំខ្វះឡើយ គ្រាន់គ្រប់បរិបូណ៌
មានតាំងអាហារ មានស្លាមានម្លូ លើកមកមិនយូរ
ចូលជូនស្វាមី ។

ហើយនាងរិះយក សំពត់អាវមក ជាហ៊ុមថ្មោងថ្មី
ស្បែកជើងនូវធ្រេ ប្រណិប័តន៍ជូនប្ដី ជាស្នៀតចៅខ្ញី
ពៅខ្មាសនរណា ។

ពោលសព្វគ្រើយ ថាស្ងួនបងអើយ បងខ្លាចបិតា
នៃប្អូនព្រលឹង ក្រែងដឹងកិច្ចការ កើតខឹងសម្បា
ធ្វើទោសទុក្ខបង ។

ហេតុនោះប្អូនអើយ កុំតូចចិត្តឡើយ ណាំនុំផ្គូនល្អន
ឈប់ចាំដល់ព្រេង សឹមតែងជាម្ដង តាមចិត្តមាសបង
ផ្គត់ផ្គង់យ៉ាងណា ។

៧៣៥. នាងស្តាប់ស្វាមី ហើយទើបស្រដី ក្ដាស់ឆ្លើយទៅថា
អ្នកគិតតែកាយ យល់ឆ្ងាយសោះសា ត្រូវដូចបបារ
មែនមិនខុសឡើយ ។

បើដូច្នោះណា យកបារីស្វា ទៅចុះអ្នកអើយ
ពិសាតាមផ្លូវ ឡើងទៅជាត្រើយ បើបានដល់ហើយ
ជំរាបមាតា ។

ឲ្យយើងពីរនាក់ បានជួបជួនជាក់ ក្នុងជាតិនេះណា
ឲ្យជាប់ដូចចង់ បំណងប្រាថ្នា កុំឲ្យអសារ
សោះសូន្យទទៅ ។

ពោធិសត្វ ទទួលយកស្លា ពិតពីប្អូនពៅ
ហើយផ្តាំថា កុំងានាងនៅ ណា ៗ នាងពៅ
កុំគិតបងឡើយ ។

បងលានុជន្ម ឡើងទៅតែខ្លួន ទេណានាងអើយ
ព្រលឹងបងនៅ ចមទៅជាត្រើយ ទំលាំហើយ
លំហែទុក្ខា ។

៧៤០– ផ្ដាំស្រេចសព្វសុស កាន់ករផ្គងចុះ ចេញចរយាត្រា
ត្រាច់កាត់ចម្រង់ ទៅក្រុងមាតា បានដល់ហើយណា
អ្នកក្រាបសំពះ ។

បីដងហើយណា លើកអស់អាហារ សែនជូនស្រឡះ
ជំរាបមាតា អស់អាថ៌ឥតខ្វះ នាងផ្ដាំពីផ្ទះ
ដូចម្ដេចគ្មានសល់ ។

ហើយបោចស្មៅផង រលីងហ្មត់ហ្មង បរិចូណ៌ប្រកល់
រួចរិះក្រាបលា មាតាដើរដល់ ទីឋានមណ្ឌល
នៃគ្រូអាចារ្យ ។

ឡើងទៅលើផ្ទះ ក្រញុំក្រាបសំពះ អង្គអាចរិយា
ហើយថយក្រោយក្រោក រេរកធ្វើការ ដូចកាលសព្វគ្រា
ពីមុនមកវិញ ។

លង់លុះបានតិច ពន្លកសពើជ្រ គន់គិតបងចេញ
វិះរកធុក ដក់ផ្លូវទំនិញ ក្រែងបានចំណេញ
កាសមួយកាសពីរ ។

៧៤៥– ឲ្យគេជីងផាន ជីងដើមឃើញប្រាណ ឃើញប្រឹងរកទី
យូរតិចអញទៅ ដោយផ្ទៅរសភី យកសំពត់ពី
ប្អូនស្ងួនសង្ហារ ។

មកស្លៀកដណ្ដប់ បន្ទិនបន្ទប់ កុំឲ្យគេថា
អ៊ីចេះអស់ចេះ ជាមោះមិនជា សន្ធុះសន្ធា
ចំពោះអញបាន ។

អ្នកគិតច្នោះហើយ ពិតពុំលង់ឡើយ លីលាចូលឋាន
ទន់ ៗ ឱបខ្លួន ទន្ទបប្រួញប្រាណ ប្រួញប្រុងបទបាន
ជំរាបអាចារ្យ ។

បពិត្រលោកគ្រូ សូមទានកាសួរ ខ្ញុំបាទនេះណា
ចង់រៀនលក់លេង លៃក្រងរកស៊ីតា មានបានដឹងការណ៍
បានដឹងណេះណោះ ។

មេបារលោកតា ឲ្យទានយាត្រា ក៏នៅផ្ទះចុះ
កុំឲ្យលក់ដូរ គិតគួរអស់នោះ ខ្ញុំបាទជាប្រុស
សមគួរដើរឆ្ងាយ ។

៧៨០— លលក់ទន្និញ អស់ទាំងទំនិញ នាំទៅកាន់ឆ្ងាយ
អាចារ្យស្តាប់ជាក់ ពាក្យអ្នកនិយាយ ដូច្នោះរួសរាយ
ស្រដីទៅថា ។

ស្រទបបេកសើច ឯងគិតត្រូវហើយ ច្នោះតាមចិន្តា
ចង់ចេះលក់ដូរ គិតគួរម្តេចម្តា ថោកថ្លៃយ៉ាងណា
ឲ្យដឹងច្បាស់ដែរ ។

វេលានេះបាន អញជាប្រធាន ជាឪជាម៉ែ
គ្រាន់នឹងឥព្យាបាល់ រក្សាមើលថែ បានជួយនាំណែ
ដឹងខុសដឹងត្រូវ ។

ចុះបើអញឯង វេភពីព្រេង មកឲ្យអាស្រូវ
ផ្តាច់ផន្ទដីភ នរណាឥឡូវ នឹងជួយគម្រូ
គម្រង់ខ្លួនឯង ។

បង្ហាញទំនុក ឲ្យស៊ីឲ្យចុក រៀនជួយចាត់ចែង
ទៅគិតនោះគាប់ ត្រូវច្បាប់ពីព្រេង តាយនោះលោកតែង
ប្រដៅច្នោះណា ។

៧៨៥— ពន្លកពង្សពុទ្ធ នុនអង្គល់ទុក ស្តាប់ពាក្យអាចារ្យ
ត្រេកអរក្នុងចិត្ត អរឥតឧបមា ករុណានោះឯតា
ចាស់ព្រឹទ្ធចូលទៅ ។

នៅក្នុងគ្រឹហា ដើរដល់ភរិយា ហើយអង្គុយនៅ
សំណេះឆ្លាស់ឆ្លើយ នាងអើយឥឡូវ នេះឯងឯទៅ
ស្រទបបេកមិញ ។

មកប្រាប់អញថា ចង់ចរយាត្រា លក់ដូរទំនិញ
ឲ្យមេតាសី នោះនៅផ្ទះវិញ គ្រាន់ប្រើចូលចេញ
នៅផ្ទះសម្បែង ។

ឯខ្លួនក៏នោះ ជាភជាប្រុស ឲ្យប្រើចាត់ចែង
ចរចេញចាកឆ្ងាយ តែកាយភឯង កុំឲ្យគិតក្រែង
បារម្ភឡើយណា ។

ចេះចូរឯងធ្វើ ធំនែកសារពើ តាមតែចិត្ត
ហើយឯងឥតខំគិត អាណិតទៅវា ដាក់ផ្ញើសឲ្យគ្នា
មួយទៀតពីរផង ។

៧៦០- គ្រាន់ជាកម្រៃ ឲ្យវាសព្វថ្ងៃ កុំខានឡើយហោង
ករយោសោកស្តាប់ សាសត្វទំនង ប្រាកព្រមល្មក់ល្មម
ឥតទោះឡើយណា ។

លន់លុះព្រឹកព្រាន កាលនោះឯងនាង ករយោអាចារ្យ
តាក់តែងបុកម្សៅ យកទៅមីម្នា លាយស្ករធ្វើជា
អាកោដាក់តែង ។

ចំហុយឆ្អិនស្រួច ត្នឹះត្នៀលរំពេច រៀបដាក់កញ្ច្រែង
គ្រប់ចំនួនសោត ក្រណាតពីរស្តែង ផ្ញើសពីរទៀតក្រែង
ឃ្លានដីតាមផ្លូវ ។

រៀបរួចស្រេចហើយ ពិតពុំលន់ឡើយ លើកហាំ ហុចទៅ
ឲ្យពាធិសត្វ បុរសគួចមទៅ វែកដើរសំដៅ
ដល់ផ្ទះនាងណ៊ាំ ។

ស្រែកតាពាយនាយ ថាអើអ្នកអាយ អ្នកកុំសង្កា
អាកោខ្ញុំផ្អែម ល្ហឹមល្ហែមពិសា បើបានភោក្តា
ភ្ញាំងភ្លេចកូនយំ ។

៧៦៤- កាកាគស់គេ មិនស្ងូវផ្អែមទេ មិនដូចផងខ្ញុំ
លោកណាទិញទៅ ពេញហៅក៏ព្ញុំ ប៉ុនពិសាខ
នៅហានស្ងួតា ។

អាកោដាក់ជូន ចំហុយយ៉ាំងហ៊ាន ឡើងពេញកន្ត្រា
ស្ករសយ៉ាំងល្អ បវរសោភា ទិញទៅពិសា
ណ៊ាំម្នាក់ថ្ងៃខ្ញុំ ។

មានតទៅភាគទីពីរទៀត